# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

**ឆ្នាំទី១ លេខ ១២** **សប្តាហ៍ទី១២ (១៣-១៦ កក្កដា ឆ្នាំ២០០៩)**


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



***រូបភាព :** សាក្សី **ហ៊ីម ហ៊ុយ** អតីតកងការពារមន្ទីរ ស-២១*

## ១. សេចក្តីផ្តើម

*"នៅសម័យនោះ. . . ត្រូវធ្វើខ្ទាក់ ធ្វើថ្លង់ ធ្វើគ ។ ប្រសិនបើទំលាយអាថិកំបាំង ខ្ញុំប្រហែលត្រូវចាប់ខ្លួន និងកំទេចហើយ"*[1]

នាសប្តាហ៍នេះ នីតិវិធីមកដល់ពាក់កណ្តាលនៃសវនាការ លើការផ្តល់សក្ខីកម្មអតីតបុគ្គលិកមន្ទីរ ស-២១ រួមមាន លោកស្រី **ណាំ ម៉ុន** លោក **ម៉ម ណៃ** និងលោក **ហ៊ីម ហ៊ុយ** ។ ការផ្តល់សក្ខីកម្មរបស់ពួកគេបានបន្ថែមឱ្យយល់កាន់តែច្បាស់ពីតួនាទី មន្ទីរ ស-២១ និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ។ **ឌុច** ទទួលស្គាល់ លោក **ម៉ម ណៃ** និងលោក **ហ៊ីម ហ៊ុយ** ថា ពិតជាអតីតបុគ្គលិកមន្ទីរ ស-២១ ធ្វើការផ្នែកសួរចម្លើយអ្នកទោស និងផ្នែកការពារ ប៉ុន្តែបដិសេធដាច់ខាតថា លោកស្រី **ណាំ ម៉ុន** មិនស្ថិតនៅក្នុងបញ្ជីឈ្មោះពេទ្យនៅមន្ទីរ ស-២១ ទេ ។

## ២. បញ្ហានីតិវិធី និងច្បាប់

### ក. សក្ខីកម្មសង្ខេបសាក្សី

នាសប្តាហ៍នេះ អតីតបុគ្គលិកមន្ទីរ ស-២១ ចំនួន ៣រូប បានកោះហៅមកផ្តល់សក្ខីកម្មក្នុងអង្គសវនាការ ។ សក្ខីកម្មរបស់ពួកគេបានបំភ្លឺកាន់តែច្បាស់ពីតួនាទីមន្ទីរ ស-២១ មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក និងតួនាទីពិតប្រាកដរបស់ **ឌុច** ក្នុងការបញ្ជាសម្លាប់អ្នកទោស ។ **ឌុច** ទទួលស្គាល់ថា លោក **ម៉ម ណៃ** និងលោកញ **ហ៊ីម ហ៊ុយ** ពិតជាបុគ្គលិកមន្ទីរ ស-២១ ប្រាកដមែន

[1] សក្ខីកម្មសាក្សី លោក ម៉ម ណៃ

ប៉ុន្តែគាត់បដិសេធដាច់ខាតថា លោកស្រី **ណាម ម៉ុន** មិនធ្លាប់ធ្វើជាពេទ្យនៅមន្ទីរសន្តិសុខទេ ។ គួរកត់សម្គាល់ លោក **ម៉ម ណៃ** បានបង្ហាញពីភាពភ័យខ្លាចក្នុងការផ្តល់សក្ខីកម្មដាក់បន្ទុកខ្លួនឯង និងបដិសេធមិនឆ្លើយតបសំណួរជាច្រើនដង ។ ខាងក្រោមនេះជាសក្ខីកម្មសង្ខេបរបស់សាក្សី ៖

**ណាំ ម៉ុន**

នីតិវិធីសប្តាហ៍មុន អង្គជំនុំជម្រះបានបញ្ឈប់សវនាការលើការផ្តល់សក្ខីកម្មលោកស្រី **ណាំ ម៉ុន** ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ កត់សម្គាល់ថា នៅព្រឹកថ្ងៃច័ន្ទ លោកស្រី **ណាំ ម៉ុន** នៅតែមានអារម្មណ៍ភ័យខ្លាច ក្នុងពេលថ្លែងប្រាប់ពីបទពិសោធន៍នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ទោះមានអ្នកតំណាងចិត្តសាស្ត្រមកពីអង្គការ Transcultural Psychosocial Organization **TPO** អមជាមួយក៏ដោយ ។

***តួនាទីជាពេទ្យនៅមន្ទីរ ស-២១ ៖*** កាលដើមដំបូងនៃសក្ខីកម្ម **ណាំ ម៉ុន** អះអាងថាខ្លួនជាពេទ្យនៅមន្ទីរ ស-២១ ។ ការលើកឡើងអត្តសញ្ញាណប័ណ្ណបង្ហាញពី *"ថ្ងៃខែឆ្នាំកំណើត"* ប្រធានអង្គជំនុំជម្រះ **និល ណុន** បានសន្និដ្ឋានថា ការចូលធ្វើពេទ្យទាហ៊ាននៅឆ្នាំ ១៩៧៥ គឺ *"មិនអាចទៅរួចទេ"* ពាក់ព័ន្ធបញ្ហានេះ លោកស្រី **ម៉ុន** បានពន្យល់ថា មីងគាត់បានផ្តល់ព័ត៌មានភាន់ច្រលំទៅរដ្ឋអំណាច ទាក់ទងនឹងថ្ងៃខែឆ្នាំកំណើតគាត់ ។ គាត់នៅតែបញ្ជាក់ថា គាត់ត្រូវរើសឱ្យធ្វើការនៅមន្ទីរសន្តិសុខនៅអាយុ ១៥ឆ្នាំ ។ គាត់ចងចាំថា បានឃើញ **ឌុច** *"ដើរជុំវិញទីបរិវេណមន្ទីរ ស-២១"* ជារៀងពីរសប្តាហ៍ម្តង ។ ទោះបីជាយ៉ាងណា នៅពេលសួរបញ្ជាក់ពីរូបថតមួយសន្លឹកនៅមន្ទីរ ស-២១ (ថតកំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ) លោកស្រី **ម៉ុន** មិនអាចចំណាំពីភិនភាគ **ឌុច** ទោះបីជាមនុស្សតែម្នាក់ក្នុងរូបថត ។

**ឌុច** បានប៉ុនប៉ងច្រានចោលសក្ខីកម្មលោកស្រី **ម៉ុន** នៅពេលមានឱកាសឆ្លើយតប ។ គាត់លើកពីកង្វះឯកសារភស្តុតាងបញ្ជាក់ពីការចុះឈ្មោះជាពេទ្យ ព្រមទាំងព័ត៌មានលើអង្គហេតុដែលថា មន្ទីរ ស-២១ ត្រូវផ្លាស់ប្តូរជាច្រើនលើកក្នុងឆ្នាំ ១៩៧៥ ទៅ ១៩៧៦ ។ **ឌុច** បន្ថែមថា ក្រុមពេទ្យនៅមន្ទីរ ស-២១ បានបញ្ចូលតែមួយកងពល ៧០៣ ដែលសុទ្ធតែជាបុរស ។ មេធាវីការពារក្តីអន្តរជាតិលោក **Roux** បានបញ្ជាក់ការគាំទ្រលើសេចក្តីអះអាងកូនក្តីខ្លួន និងបដិសេធលើភាពអាចជឿជាក់ពីសក្ខីកម្មលោកស្រី **ម៉ុន** មិនចងចាំចំណុចសំខាន់អតីតប្រធានមន្ទីរ ស-២១ និងបង្ហាញឱ្យឃើញនូវកង្វះការយល់ដឹងពីតំបន់សម្ងាត់ ព្រមទាំងមិនដឹងពីទីតាំងមុនរបស់មន្ទីរ ស-២១ ។

***អត្តសញ្ញាណញាតិលោហិតសាក្សី ៖*** នៅពេលដេញដោលដោយសហព្រះរាជអាជ្ញាជាតិ លោកស្រី **ម៉ុន** បានរៀបរាប់លំអិតពីវិធីដែល **ឌុច** បានសម្លាប់ពូគាត់ទាំងពីរដោយផ្ទាល់ដៃ ឈ្មោះ **ពូ អឿន** និង **ពូ កេត** ។ គាត់រៀបរាប់ថា ពូគាត់ត្រូវសម្លាប់បន្តបន្ទាប់ត្រឹមតែ *"ពីទៅបីថ្ងៃប៉ុណ្ណោះ"* ។ គាត់ចងចាំថា វិធីដែល **ឌុច** ប្រើគឺវាយពូគាត់រហូតដល់ស្លាប់ *"ក្រោមដើមដូង"* ខាងក្រៅរបងមន្ទីរ ស-២១ ។ លោកស្រី **ម៉ុន** បានបន្ថែមថា ការថ្លោះសិទ្ធិលើកបញ្ហានេះក្នុងពាក្យបណ្តឹង ដោយមូលហេតុតក់ស្លុត និងភ័យខ្លាចបណ្តាលឃើញ *"ការសម្លាប់មនុស្ស"* និងការស្ទាក់ស្ទើរមិនចងបញ្ចូល *"ឈ្មោះច្រើន"* នៅក្នុងពាក្យបណ្តឹង ។

***លក្ខខណ្ឌអំពើហិង្សា និងការសម្លាប់មនុស្ស :*** ការចងចាំពីបទពិសោធន៍នៅមន្ទីរអប់រំកែប្រែព្រៃស លោកស្រី **ម៉ុន** បានបង្ហាញឱ្យដឹងថា គាត់បានឃើញ *"ក្មេងម្នាក់ ឬពីរនាក់"* ត្រូវ *"បោះពីលើអាគារខ្ពស់"* និងចាក់សម្លាប់នឹងចំពុះទុង ដែលនេះបង្ហាញពីឧបករណ៍ថ្មីផ្សេងទៀត ដែលងាកចេញពីសក្ខីកម្មមុនៗ ។ លោកស្រីបានឱ្យដឹងថា មន្ទីរអប់រំកែប្រែព្រៃសជា *"កន្លែងដែលស្ត្រី និងកុមារត្រូវបានសម្លាប់"* និងនៅទីបរិវេណមន្ទីរអប់រំកែប្រែព្រៃសមាន *"សាកសព"* ។

## ម៉មណៃ

នៅថ្ងៃអង្គារ និងថ្ងៃប្រហស្បតិ៍ នីតិវិធីបានមកដល់ពាក់កណ្ដាលនៃការផ្ដល់សក្ខីកម្មរបស់លោក **ម៉ម ណៃ** អាយុ ៧៦ឆ្នាំ ជាអតីតអ្នកសួរចម្លើយនៅមន្ទីរ ស-២១ ។ លោក **ម៉ម ណៃ** សព្វថ្ងៃរស់នៅខេត្តបាត់ដំបង គាត់បានរៀបរាប់ពីបទពិសោធន៍ខ្លួនក្នុងនាមជាសមាជិកបុគ្គលិកមន្ទីរសន្តិសុខ ។ គួរកត់សម្គាល់ លោក **ម៉ម ណៃ** បានសំអាងលើសិទ្ធិមិនដាក់ពិរុទ្ធលើខ្លួនឯងជាច្រើនលើកកំឡុងពេលផ្ដល់សក្ខីកម្ម ។ គាត់បានលើកឡើងថា ការចងចាំពីព្រឹត្តការណ៍ជាក់លាក់មួយចំនួនអាចមានការភាន់ច្រលំ ដោយសារគ្រោះថ្នាក់ ដូច្នេះក៏រិតចងចាំធ្លាក់ចុះ ។

***ការចូលរួមដំណាក់កាលដំបូងក្នុងចលនាកុម្មុយនិស្ត :*** លោក **ម៉ម ណៃ** បានបរិយាយយ៉ាងលម្អិតអំពីការចូលរួមនៅដំណាក់កាលដំបូងជាមួយចលនាកុម្មុយនិស្តប្រទេសកម្ពុជា ។ មុនឆ្នាំ ១៩៧០ រដ្ឋាភិបាលសម្ដេចព្រះនរោត្តមសីហនុបានចាប់ខ្លួនគាត់ដោយចោទប្រកាន់ពីការចូលរួមចលនាបដិវត្តន៍ខ្មែរក្រហម ហើយឃុំខ្លួនអស់រយៈពេល ២ឆ្នាំ ។ លោក **ម៉ម ណៃ** បានពន្យល់ពីការបង្កើតចំណងមិត្តភាពជាមួយ **ឌុច** កំឡុងពេលជាប់ឃុំឃាំង ។ ក្រោយពីការដោះលែង ការពាក់ព័ន្ធគាត់ជាមួយបក្សកុម្មុយនិស្តកម្ពុជាបានកើតមានឡើង ដោយសារការនិយមលទ្ធិកុម្មុយនិស្ត និងនិន្នាការនិយមមនោគមវិជ្ជានៃការរំដោះវណ្ណៈកសិករ ។ គាត់បានបន្ថែមថា ជាបន្តបន្ទាប់គាត់បានបង្ខំខ្លួនឯង *"ដើម្បីស្ដាបនាចិត្តសាស្ត្រ ជំហ និងទស្សនៈ"* ដោយអនុលោមតាម *"មាគ៌ានយោបាយ"* ដែលបក្សបានលើកតម្កើង។

***តួនាទីនៅមន្ទីរ ស-២១ និងរចនាសម្ព័ន្ធអង្គការលេខ :*** លោក **ម៉ម ណៃ** ហាក់មានការស្រពិចស្រពិលទទួលយកថា ជាលទ្ធផលការចាត់តាំងគាត់នៅមន្ទីរ ស-២១ បានឆ្លុះបញ្ចាំងពីតួនាទីគាត់នៅមន្ទីរ ម-១៣ ។ គាត់បានពិពណ៌នាខ្លួនឯងថា *"គាត់ជាកម្មាភិបាលសួរចម្លើយស្មោះត្រង់ និងសាមញ្ញ"* ។ គាត់អះអាងច្រំដែលៗថា *"គាត់មានតួនាទីមិនសំខាន់ទេនៅមន្ទីរ ស-២១"* ។ គាត់ផ្ដល់សក្ខីកម្មថា គាត់បានធ្វើការពុះពារដាក់ខ្លួនឯងឱ្យឆ្ងាយពីប្រតិបត្តិការប្រចាំថ្ងៃនៅការិយាល័យសន្តិសុខ ។ លោក **ម៉ម ណៃ** បានបន្ថែមថា ការរស់រានមានជីវិតរបស់គាត់ គឺដោយហេតុ *"ធ្វើខ្វាក់ ធ្វើថ្លង់"* ចំពោះអំពើយង់ឃ្នងប្រព្រឹត្តនៅទីនោះ ។

គាត់បានបញ្ជាក់ថា *"គាត់មិនដឹងច្បាស់"* ពីសមាសភាពអ្នកជាប់ឃុំឃាំង ឬពីស្ថានភាពពាក់ព័ន្ធនឹងការឃុំឃាំងនៅមន្ទីរ ស-២១ ឡើយ ប៉ុន្តែគាត់សន្និដ្ឋានថា អ្នកជាប់ឃុំឃាំងនៅមន្ទីរ ស-២១ *"ស្ថានភាពកាយសម្បទារបស់ពួកគេហាក់មានសុខភាពល្អ"* នៅពេលចូលកន្លែងសួរចម្លើយ ។ គាត់អះអាងថា គាត់មិនបានដឹងអំពីវិធីចាប់អ្នកទោស និងចំនួនបុគ្គលិកធ្វើការនៅការិយាល័យ

សន្តិសុខទេ ។ គាត់បានលើកឡើងពីវប្បធម៌គោរពបញ្ជាអង្គភាព ដោយពន្យល់ថា គាត់បានគោរពដោយឥតប្រកែកចំពោះបទបញ្ជាមេលើការហាមឃាត់ *"មិនឱ្យដើរជុំវិញបរិវេណមន្ទីរ ស-២១"* ។ លោកស្រីចៅក្រម **Cartwright** បានចោទសួរពីសច្ចភាពនៃការចោទប្រកាន់ទាំងនេះដោយគូសបញ្ជាក់ពីភាពមិនគួរជឿបាន ដោយសារថា *"មនុស្សដែលមានការអប់រំខ្ពស់ និងឆ្លាត"* ដូចលោក **ម៉ម ណៃ** *"មិនបានយល់ដឹងច្រើននូវព្រឹត្តការដែលបានកើតឡើង"* នៅជុំវិញបរិវេណកន្លែងគាត់ធ្វើការ ។ ចំពោះការយល់ដឹងរបស់គាត់ទាក់ទងនឹងគោលនយោបាយឈ្លះៗនាពេលនោះ គាត់បានបដិសេធនូវការទទួលស្គាល់ថា អ្នកទោសមិនត្រូវបានផ្តន្ទាទោសដល់ជីវិតតាំងដំបូង ។ ការលើកឡើងមួយទៀត គាត់បានអះអាងពីការមិនបាន ចងចាំនូវការប្រល័យជីវិតមនុស្សនៅជើងឯក ។

***ការសួរចម្លើយ :*** លោក **ម៉ម ណៃ** បានផ្តល់សក្ខីកម្មថា អង្គការចាត់តាំងគាត់សួរចម្លើយតែ *"កម្មាភិបាលថ្នាក់ទាបប៉ុណ្ណោះ"* ។ ការសួរចម្លើយធ្វើឡើងនៅផ្ទះសួរចម្លើយខាងកើតបរិវេណមន្ទីរ ស-២១ ជាទូទៅធ្វើនៅពេលអវត្តមានមេគាត់ ។ ទោះបីជា គាត់បានអះអាងតាំងពីដំបូងថា **ឌុច** មិនដែលមើលការសួរចម្លើយ គាត់បានផ្លាស់ប្តូរជំហរនៅពេលតទល់នឹងភាពផ្ទុយគ្នាពីអំណះអំណាងមុនចំពោះមុខចៅក្រមស៊ើបអង្កេត ។ ចំពោះការសួរចម្លើយអ្នកទោសជនជាតិវៀតណាមនៅមន្ទីរ ស-២១ គាត់អះអាងថា គាត់បានសួរចម្លើយយុទ្ធជនវៀតណាមតែពី ១០-២០នាក់ ប៉ុណ្ណោះ និងជនស៊ីវិលវៀតណាមតែ ២-៣នាក់ ដែលបានចាប់ខ្លួននៅសមរភូមិ ។ សហព្រះរាជអាជ្ញារងអន្តរជាតិ លោក **William Smith** បានបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវភាពមន្ទិលសង្ស័យអំពីតួលេខ លោកសហព្រះរាជអាជ្ញាធ្វើនិទស្សន៍ថា លោក **ម៉ម ណៃ** តាមពិតទៅបានសួរចម្លើយយុទ្ធជន និងចារកម្មវៀតណាមជាង ២០០នាក់ ប៉ុន្តែកិច្ចប្រឹងប្រែងរបស់សហព្រះរាជអាជ្ញាបានទទួលជោគជ័យតែអន្លើប៉ុណ្ណោះ ដោយសារសាក្សីប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយ ។ លោក **ម៉ម ណៃ** បានបញ្ជាក់ដោយសមហេតុផលនូវការអះអាងពីមុនរបស់ **ឌុច** ថា ចម្លើយសារភាពអ្នកទោសវៀតណាមបានផ្សព្វផ្សាយតាមវិទ្យុ ។

***ការរំជួលចិត្តរបស់សាក្សី (សោកស្តាយនូវអ្វីដែលបានកើតឡើង) :*** នៅពេលសួរថាតើមានការសោកស្តាយចំពោះតួនាទីខ្លួននៅមន្ទីរ ស-២១? លោក **ម៉ម ណៃ** បានសំដែងនូវការសោកស្តាយជាពន្លឹកចំពោះ *"មនុស្សល្អ"* ត្រូវបានកំទេចដោយកណ្តាប់ដៃបុគ្គលិកមន្ទីរ ស-២១ ប៉ុន្តែ *"មិនសោកស្តាយចំពោះមនុស្សអាក្រក់"* ដែលត្រូវបោសសំអាតនៅការិយាល័យសន្តិសុខ ។ គូសបញ្ជាក់ពីភាពខុសគ្នាយ៉ាងខ្លាំងរវាងការភ្ញាក់រលឹករបស់ **ឌុច** និងភាពព្រងើយកន្តើយរបស់ **ម៉ម ណៃ** ចំពោះឧក្រិដ្ឋកម្មកើតឡើងនៅមន្ទីរ ស-២១ លោក François Roux បានសំដែងនូវការអរគុណការិយាល័យសហព្រះរាជអាជ្ញាក្នុងការកោះហៅសាក្សីរូបនេះចូលផ្តល់សក្ខីកម្ម ។ លោក **ឌុច** បានរំលឹកលោក **ម៉ម ណៃ** ថា *"លទ្ធិកុម្មុយនិស្ត"* មិនគម្បីរារាំងនូវការលាតត្រដាងការពិតទេ ក្នុងទទួលស្គាល់តួនាទីខ្លួនក្នុងការបំផ្លាញប្រជាពលរដ្ឋខ្មែរអស់ជាង ១.៨លាននាក់ ហើយ *" គាត់ព្រមទទួលខុសត្រូវខាងផ្លូវចិត្ត"* ចំពោះទង្វើរបស់គាត់។ ក្រោយពីការដាស់តឿនលោក **ម៉ម ណៃ** បានប្តូរចារិកដោយសំដែង *"ការសោកស្តាយ"* ចំពោះវាសនារបស់ជនរងគ្រោះស្លាប់ក្រោមកណ្តាប់ដៃគាត់ដោយសម្រក់ទឹកភ្នែក ។ ខណៈរៀបរាប់ឡើងវិញនូវអ្វី ដែលសមាជិកគ្រួសារបាន

ថ្កោលទោសចំពោះទុក្ខវេទនាក្រោមរបបនេះ លោក **ម៉ម ណៃ** បានទទួលស្គាល់ថា លោកគ្មានអំណាច *"ធ្វើអ្វីផ្សេងបានទេ"* ក្រៅពីការសោកស្តាយប៉ុណ្ណោះ ។

## *ហ៊ឹម ហ៊ុយ*

នៅរសៀលថ្ងៃពុធ អង្គជុំជម្រះបានកោះហៅ លោក **ហ៊ឹម ហ៊ុយ** ដែលមានអាយុ៥៤ឆ្នាំ បច្ចុប្បន្ននេះស្នាក់នៅស្រុកកោះធំ ខេត្តកណ្តាល។ អង្គជំនុំជម្រះបានប្រាប់គាត់ជាមុនអំពីសិទ្ធិ ដើម្បីពិគ្រោះជាមួយមេធាវីរបស់គាត់។ លោក **ហ៊ឹម ហ៊ុយ** បានបន្តផ្តល់សក្ខីកម្ម ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវតំលៃអំពីប្រតិបត្តិការនៅមន្ទីរ ស-២១ និងការប្រល័យជីវិតអ្នកទោស ។ ទោះបីជាគាត់ផ្លាស់ប្តូរចំណុចជាច្រើនកំឡុងសក្ខីកម្ម ជាទូទៅលោក **ហ៊ឹម ហ៊ុយ** បានអះអាងប្រកបដោយស្មារតីរឹងមាំ ខណៈរៀបរាប់អំពីការចូលរួមរបស់គាត់ក្នុងការកាប់សំលាប់មនុស្សអស់រាប់ពាន់នាក់ ។

***ការចាប់ខ្លួន និងការផ្ទេរអ្នកទោសទៅមន្ទីរ ស-២១ :*** សក្ខីកម្មរបស់លោក **ហ៊ឹម ហ៊ុយ** បានបំភ្លឺយ៉ាងច្បាស់អំពីបែបបទនៃការចាប់ខ្លួន និងការចាប់ខ្លួនជាស្រេចនៅតាមតំបន់ និងអង្គភាពនានា ។ គាត់បានគូសបញ្ជាក់ថា អ្នកទោសទាំងនោះត្រូវបង្ខំឱ្យទ្រាំនឹងភាពពិបាកនៅពេលចូលមន្ទីរ ស-២១ ដោយការចងមុខ ដាក់ខ្នោះដៃ និងជើង ហើយហាមមិនឱ្យកម្រើកខ្លួន ។ នៅពេលខ្លះអង្គភាពអាចទទួលអ្នកទោសនៅការិយាល័យសន្តិសុខរបស់ខ្លួន មុនពេលនាំពួកគេចូលទៅ មន្ទីរស-២១ ។ ចំពោះអ្នកទោសចាប់ដោយអង្គភាពខ្លួន **ហ៊ុយ** បានឱ្យដឹងថា ភាគច្រើនចាប់នៅភ្នំពេញ ។ គាត់បន្ថែមថា ការចាប់ទាំងនេះធ្វើឡើងនៅពេលយប់ ។ តាមការសន្និដ្ឋាន ដើម្បីចៀសវាងការមើលឃើញប្រតិបត្តិការសម្ងាត់ក្នុងគុក ។ គាត់ក៏បានបញ្ជាក់នូវការពិតថា *"ល្បិច"* ត្រូវបានប្រើដើម្បីសម្រួលដល់ការចាប់ជាទ្រង់ទ្រាយធំក្រុមនិស្សិតមួយក្រុមមកពីបរទេស ។ គាត់បានបញ្ជាក់ថាគ្រប់ប្រតិបត្តិការទាំងអស់ធ្វើឡើងដោយមានបញ្ជាចេញពី **ឌុច** ។

***ការសម្រិតសម្រាំងផ្ទៃក្នុង :*** ចំពោះការសម្រិតសម្រាំងផ្ទៃក្នុងត្រូវបោសសំអាតនៅមន្ទីរសន្តិបាល លោក **ហ៊ុយ** បានរៀបរាប់ពីបុគ្គលិកមន្ទីរ ស-២១ ជាច្រើន ពិសេសកម្មាភិបាលកងពល ៧០៣ ឈានដល់ការបោសសំអាតរហូតដល់ ៧០% ។ លោក **ហ៊ុយ** អះអាងបន្ថែមថា អ្នកក្រោមបង្គាប់ **ឌុច** ក៏ផ្តល់អំណាចក្នុងការចាប់ខ្លួនបុគ្គលិកមន្ទីរ ស-២១ ដែរ ។

***វាលពិឃាតជើងឯក*** : លោក **ហ៊ុយ** រៀបរាប់ថា ជើងឯកត្រូវប្រើជាកន្លែងពិឃាតនៅឆ្នាំ ១៩៧៧ ។ គាត់ទទួលស្គាល់ថា គាត់បានដឹកជញ្ជូនអ្នកទោសទាំងឡាន៧ទៅវាលពិឃាតជើងឯក និងសម្លាប់អ្នកទោសយ៉ាងហោចណាស់ម្នាក់នៅទីនោះ ។ គាត់ពន្យល់ថាកំឡុងពេលដឹកបញ្ជូនទៅជើងឯក អ្នកទោសទាំងអស់ត្រូវបានដាក់ខ្នោះ និងចងមុខ ដោយប្រាប់ថា ត្រូវផ្លាស់ទៅ *"ផ្ទះថ្មី"* ។ នៅពេលឡានចូលដល់ជើងឯក អ្នកទោសទាំងអស់ត្រូវប្រមូលដាក់ផ្តុំនៅផ្ទះតូចមួយ ហើយត្រូវផ្ទៀងផ្ទាត់ឈ្មោះម្តងទៀតជាមួយ *"បញ្ជីកំទេច"* រៀបចំជាមុនដោយ **សួស ធី** ដែលជាប្រធានទទួលបន្ទុកខាងផ្នែកឯកសារ។ លោក **ហ៊ុយ** បានរំលឹកដោយសមហេតុផលមួយថា ការសម្លាប់នៅមន្ទីរ ស-២១ ក៏មានលក្ខណៈជាប្រព័ន្ធដូចនឹងការសម្លាប់នៅជើងឯកដែរ ។ តាមសក្ខីកម្មគាត់បានឱ្យ

ដឹងថា កុមារ ឈ្លើយសឹករៀតណាម អតីតបុគ្គលិកមន្ទីរ ស-២១ និងកម្មាភិបាលសំខាន់ៗ ត្រូវបន្តបោសសំអាតនៅខាងក្នុង ឬជុំវិញបរិវេណមន្ទីរ ស-២១ ។

## ២. បញ្ហាផ្នែកច្បាប់កើតមានកំឡុងពេលសវនាការ :

***សហឧក្រិដ្ឋកម្មរួម និងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង*** : ភាពគ្រប់គ្រាន់នៃព័ត៌មានដែលផ្តល់ដល់សាក្សីទាំងឡាយ ជាពិសេសទាក់ទងនឹងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង បានធ្វើឱ្យមានការពិភាក្សាដេញដោលរវាងភាគីទាំងសងខាងពេញមួយសប្តាហ៍ ។ នៅថ្ងៃច័ន្ទ លោក François Roux បានបញ្ចេញកង្វល់ខ្លួនថា សាក្សីលោក **ម៉ម ណៃ** មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីភាពប្រថុយប្រថានក្នុងការប្រឈមមុខនឹងការចោទប្រកាន់ ប្រសិនបើអង្គជំនុំជម្រះយល់ព្រមទទួលយកសំណើដាក់ជូនដោយការិយាល័យសហព្រះរាជអាជ្ញា កាលពីថ្ងៃទី០៨ មិថុនា ២០០៩ ( សូមមើល *ការដាក់សំណើពីការិយាល័យសហព្រះរាជអាជ្ញាអំពីសហឧក្រិដ្ឋកម្មរួម*) ។ កថាខណ្ឌ ៩ នៃសំណើនេះគាំទ្រដល់ការអនុវត្ត **JCE** (សហឧក្រិដ្ឋកម្មរួម) នឹងកិច្ចនីតិវិធីបច្ចុប្បន្ន គឺពិចារណាលើ **ឌុច** និង *"ទាំងអ្នកនៅក្រោមបង្គាប់នៃមន្ទីរ ស-២១"* អំពីពិរុទ្ធភាពនៃសហឧក្រិដ្ឋកម្មរួម ។ ស្របគ្នានោះ លោក Roux ស្នើឡើងថា សាក្សីគួរទទួលបានឱកាសពិគ្រោះយោបល់ជាមួយមេធាវី មុនពេលផ្តល់សក្ខីកម្ម ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក **William Smith** ឆ្លើយតបថា លោក **ម៉ម ណៃ** ទទួលរួចនូវការ *"ធានាអះអាង"* ពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយច្រានចោលការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. ។ ទោះជាយ៉ាងណា លោក **Roux** បានអះអាងថា ការិយាល័យសហព្រះរាជអាជ្ញាមិនមានគោលជំហក្នុងការការពារលោក **ម៉ម ណៃ** ប្រឆាំងនឹងលទ្ធភាពនៃការចោទប្រកាន់នៅចំពោះមុខតុលាការជាតិ ។ តាមការពិភាក្សារវាងភាគីទាំងពីរ លោក **ម៉ម ណៃ** បានសុំសិទ្ធិក្នុងការពិគ្រោះយោបល់ជាមួយមេធាវីដោយអនុលោមតាមវិធាន ២៨ (៩) នៃវិធានផ្ទៃក្នុង ។

លោក **William Smith** បានបកស្រាយលើការលើកឡើងរបស់ **Roux** និងជំរុញឱ្យមានការការពារសិទ្ធិសាក្សីបន្ថែមទៀត នាពេលអនាគត ។ លោកបានអះអាងថា **Roux** ខកខានមិនបានអនុវត្តតាមវិធាន ២៨ (៨) នៃវិធានផ្ទៃក្នុង ព្រមទាំងធ្វើឱ្យសាក្សីមានការភ័យខ្លាច ។ លោក **Smith** បានលើកថា ពាក្យស្នើសុំទាក់ទិននឹងសហឧក្រិដ្ឋកម្មរួមនៅក្នុងកិច្ចនីតិវិធីបច្ចុប្បន្នមិនផ្លាស់ប្តូរទិដ្ឋភាពផ្នែកច្បាប់ពាក់ព័ន្ធនឹងសក្ខីកម្មប្រឆាំងខ្លួនឯងទេ ដោយហេតុថា អតីតបុគ្គលិកមន្ទីរ ស-២១ ទាំងអស់នៅតែទទួលខុសត្រូវរងការចោទប្រកាន់នៅក្រោមទ្រឹស្តីផ្សេងៗទៀតនៃផ្នែកព្រហ្មទណ្ឌ ប៉ុន្តែលោកបានគូសបញ្ជាក់ថា លទ្ធភាពនៃការចោទប្រកាន់លោក **ម៉ម ណៃ** គឺមាន *"ភាពដាច់ឆ្ងាយខ្លាំងណាស់"* ។

ជាការឆ្លើយតប លោក **Roux** បានស្នើសុំថា ការិយាល័យសហព្រះរាជអាជ្ញាត្រូវដកសំណើទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមរបស់ខ្លួន ធ្វើដូច្នេះភាគីនឹងមានអារម្មណ៍ *"មានការធានាច្រើនជាងនេះ"* ។ នៅពេលលោក **Roux** ធ្វើការបញ្ជាក់ពីកង្វល់ខ្លួនម្តងទៀត អំពីបញ្ហា *"ការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង"* កំឡុងពេលកិច្ចនីតិវិធីនៅថ្ងៃពុធ លោកប្រធានអង្គជំនុំជម្រះ **និល ណុន** ហាក់ជាមានការច្រលោតខឹងយ៉ាងខ្លាំង ។ បន្ទាប់ពីផ្អាកសវនាការរយៈពេល ២០នាទី លោកប្រធានបានដាស់តឿនភាគីទាំងពីរមិនឱ្យមានការលើកឡើងនូវបញ្ហានេះកំឡុងពេលផ្តល់សក្ខីកម្មសាក្សីឡើយ ។

## ៣. ការចូលរួម និងការគាំពារសាក្សី និងជនរងគ្រោះ

***ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី*** ៖ តំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩រូប មានវត្តមានបីថ្ងៃដំបូងនៃកិច្ចនីតិវិធីនាសប្តាហ៍នេះ ប៉ុន្តែចំនួននេះបានកើនឡើងដល់ ១០រូប នៅកិច្ចដំណើការនីតិវិធីថ្ងៃព្រហស្បតិ៍ ។

***ការគាំពារសាក្សី និង ជនរងគ្រោះ*** ៖ នាសប្តាហ៍នេះ អង្គជំនុំជម្រះបានបន្តយកចិត្តទុកដាក់ចំពោះផ្នែកស្មារតីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ដោយការអនុញ្ញាតិឱ្យសម្រាកនៅកិច្ចដំណើរការនីតិវិធី នៅពេលដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវការឈឺចាប់ខាងអារម្មណ៍ ដែលនេះជាកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះ *(ក្រុមអ្នកឃ្លាំមើលតុលាការសូមកោតសរសើរ)* ។

ជាការឆ្លើយតប ការបង្ហាញពីអស្ថេរភាពផ្នែកសតិអារម្មណ៍របស់លោកស្រី **ណាំ ម៉ុន** កាលពីនីតិវិធីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន ដើមបណ្តឹងរដ្ឋប្បវេណីត្រូវអមដោយបុគ្គលិកចិត្តសាស្ត្រអង្គការ **TPO** កំឡុងពេលផ្តល់សក្ខីកម្មនៅថ្ងៃច័ន្ទ ដែលធ្វើឱ្យលោកស្រីមានអារម្មណ៍ល្អជាងមុន និងអារម្មណ៍ស្ងប់នៅពេលឆ្លើយសំណួរ ។

***សិទ្ធិ និងករណីយកិច្ចសាក្សីនៅក្រោមវិធានផ្ទៃក្នុង*** ៖ មុនឈានដល់ការផ្តល់សក្ខីកម្ម លោក **ម៉ម ណៃ** ត្រូវបានប្រាប់សិទ្ធិយោងតាមវិធាន ២៨(១) នៃវិធានផ្ទៃក្នុង ។ ទោះយ៉ាងណា អង្គជំនុំជម្រះខកខានមិនប្រាប់ពីកាតព្វកិច្ចយោងតាមវិធាន ៣៦(១) តម្រូវឱ្យ *"គាត់និយាយការពិត"* នូវព្រឹត្តការណ៍ដែលថា គាត់បដិសេធមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង ។ ក្រុមឃ្លាំមើលតុលាការកត់សម្គាល់ថា សាក្សីទាំងឡាយត្រូវបានប្រាប់មិនដែលខានថា ពួកគេត្រូវ *"និយាយការពិត"* នូវអ្វីដែលបានឃើញ បានដឹង និងបានឮ ប៉ុន្តែពួកគេមិនត្រូវបានប្រាប់អំពីផលបច្ច័យអាចកើតមានពីការខកខានមិនអនុវត្តតាមឡើយ ។

***មេធាវីដើមបណ្តឹងរក្សាសម្លេងជនរងគ្រោះ :*** នាសប្តាហ៍នេះ លោកស្រីមេធាវី **Silke Studzinsky** ហាក់សង្កត់ធ្ងន់ជាពិសេសលើតួនាទីគាត់ថា *"រក្សាសម្លេង និងបង្ហាញពីក្តីកង្វល់កូនក្តីខ្លួន"* ។ នៅពេលដល់វេណសួរដេញដោលសាក្សី **ម៉ម ណៃ** លោកស្រី **Studzinsky** បានតាំងសំណួរក្នុងគោលបំណងចង់បានព័តិមានពីជោគវាសនារបស់សាស្ត្រាចារ្យ **ភឹង តុន** (ឃុំខ្លួននៅមន្ទីរ ស-២១) ដែលនេះហាក់បានបង្ហាញថា លោកស្រីដើរតួនាទីតំណាងឱ្យប្រពន្ធ និងកូនលោកសាស្ត្រាចារ្យ ។ ទោះបីជា អង្គជំនុំជម្រះមិនបានសម្រេចឱ្យច្បាស់ពីតួនាទីដើមបណ្តឹងរដ្ឋប្បវេណី ក៏លោកស្រី **Studzinsky** ហាក់បានបង្ហាញពីចេតនាក្នុងការកម្រិតតួនាទីខ្លួន ។ ទង្វើនេះ គឺជាការអនុវត្តគួឱ្យកោតសរសើរ ។

***ការច្រានចោលសំណើសុំវិធានការណ៍ការពារសាក្សី KW-10***: នារសៀលថ្ងៃព្រហស្បត្តិ៍ អង្គជំនុំជម្រះបានប្រកាសសេចក្តីសម្រេចអំពីសំណើសុំវិធានការណ៍ការពារសាក្សី ***KW-10*** ។ បន្ទាប់ពីពិនិត្យលើការវាយតម្លៃ និងកម្រិតហានិភ័យ ដែលធ្វើឡើងជាសម្ងាត់នោះ អង្គជំនុំជម្រះបានច្រានចោលសំណើសុំវិធានការណ៍ការពារពិសេស ដោយហេតុផលថា សាក្សីរូបនេះត្រូវបានស្គាល់ជាទូទៅ និងបានដឹងពីតួនាទីគាត់ជាអ្នកសួរចម្លើយនៅមន្ទីរ ស-២១ ។ អង្គជំនុំជម្រះបញ្ជាក់បន្ថែមថា ការសម្រេចនេះ គឺស្របនឹងអនុសាសន៍ផ្តល់ឱ្យដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។

## ៤. ការគ្រប់គ្រងការសវនាការ

***ការគ្រប់គ្រងរបស់តុលាការ :*** និយាយជារួមកិច្ចនីតិវិធីនាសប្តាហ៍នេះប្រព្រឹត្តយ៉ាងមានប្រសិទ្ធិភាពខ្ពស់ ។ អង្គជំនុំជម្រះចាប់ផ្តើមសវនាការ និងការសម្រាកយ៉ាងទៀងទាត់ពេលវេលា ក្រុមអ្នកឃ្លាំមើលមានការកោតសរសើចំពោះទង្វើនេះ ។ ទោះបីយ៉ាងណាអង្គជំនុំជម្រះបានបញ្ឈប់សវនាការមុនម៉ោងកំណត់ ១ម៉ោង នៅថ្ងៃចន្ទ និងថ្ងៃអង្គារ ព្រោះតែសាក្សី ២រូប ចង់ពិគ្រោះយោបល់ជាមួយមេធាវីខ្លួនសិន មុននឹងឆ្លើយបំភ្លឺដល់អង្គសវនាការ ។

***ការរៀបចំកន្លែងឱ្យមេធាវីសាក្សី :*** នៅព្រឹកថ្ងៃអង្គារ មេធាវីការពារក្តីអន្តរជាតិលោក **Roux** បានលើកឡើងពីការសង្កេតរបស់ខ្លួន អំពីការរៀបចំកន្លែងអង្គុយរបស់មេធាវីសាក្សីថ្មីនៅជាប់ផ្នែកមេធាវីការពារក្តី ។ លោក **Roux** បានបញ្ជាក់ថា ការឱ្យមេធាវីសាក្សីអង្គុយនៅផ្នែកខាងមេធាវីការពារក្តី គឺមិនខុសពីការសម្រេចជាមុនលើសំណើរបស់សហព្រះរាជអាជ្ញាឱ្យពិចារណាពីលទ្ធភាពលោក **ម៉ម ណៃ** ថាអាចជាជនជាប់ចោទ ។ កង្វល់មេធាវីការពារក្តីនេះត្រូវបានគាំទ្រដោយមេធាវីដើមបណ្តឹងក្រុម៣ លោកស្រី **Jacquine** ។ ចំពោះភាគីសហព្រះរាជអាជ្ញាលោក **William Smith** បានលើកឡើងថា សេចក្តីសន្និដ្ឋានរបស់លោក **Roux** បានបង្កើតឱ្យមានចំណាប់អារម្មណ៍ជាអវិជ្ជមានអំពីការចាត់ចែងកន្លែងអង្គុយរបស់មេធាវីសាក្សី ។ ប្រធានអង្គជំនុំជម្រះ **និល នន់** បានពន្យល់ថា កន្លែងអង្គុយរបស់មេធាវីសាក្សីនៅផ្នែកមេធាវីការពារក្តី គឺសមរម្យ ព្រោះទីតាំងនោះមេធាវីអាចនៅជិតកូនក្តីខ្លួន ។ បន្ថែមលើនេះ លោកប្រធានបានបញ្ជាក់ជាថ្មីថា នេះជាអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការចាត់ចែងកិច្ចនីតិវិធី ។

***វត្តមានភាគី :*** មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ លោក **ហុង គីមសួន** អវត្តមានពីរថ្ងៃដំបូង និងរសៀលថ្ងៃព្រហស្បតិ៍នៃសវនាការសប្តាហ៍នេះ ។

លោក **Anees Ahmed** តំណាងសហព្រះរាជអាជ្ញាអន្តរជាតិនៅព្រឹកថ្ងៃចន្ទ និងលោក **William Smith** តំណាងនៅថ្ងៃសវនាការបន្តបន្ទាប់ ។ ចំណែកឯសហព្រះរាជ្ញាជាតិ តំណាងដោយ លោក **សេង ប៊ុនខេង** នៅថ្ងៃច័ន្ទ និងលោក **តាំង សេណារ៉ុង** មានវត្តមានបីថ្ងៃ ។

មេធាវីការពារក្តីទាំងភាគីជាតិ និងអន្តរជាតិមានវត្តមានពេញមួយសប្តាហ៍ ។ ចំពោះមេធាវីសាក្សីវិញលោក **គង់ សំអុន** ក៏មានវត្តមានពេញមួយសប្តាហ៍ដែរ ។

***វត្តមានសាធារណៈជន :*** នាសប្តាហ៍នេះ សាធារណៈជនចូលរួមតាមដានសវនាការមានចំនួនយ៉ាងច្រើន ដោយសារមានការជួយឧបត្ថម្ភពីផ្នែកកិច្ចការសាធារណៈរបស់សាលាក្តី ។ អង្គភាពនេះបានជួយសម្រួលដល់ការចូលរួមរបស់អ្នកភូមិ ក្រុមសិស្ស និស្សិតជារៀងសប្តាហ៍ ។ នៅថ្ងៃចន្ទ ប្រជាពលរដ្ឋចំនួន ៣០០នាក់ មកពីឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល និងនិស្សិតប្រមាណជា ៧០នាក់ មកពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចូលរួមសវនាការ ។ ចំណែកនៅថ្ងៃអង្គារ ប្រជាពលរដ្ឋចំនួន ២០០នាក់ មកពីស្រុកកៀនស្វាយ ។ នៅថ្ងៃព្រហស្បតិ៍ ប្រជាពលរដ្ឋប្រមាណជា ៤៦០នាក់ មកពីឃុំបារាយ ស្រុកបារាយក្នុងខេត្តកំពង់ធំ រួមជាមួយនិស្សិតប្រមាណជា ១០០នាក់ មកពីសកលវិទ្យាល័យពុទ្ធិសាស្ត្រ មានវត្តមានពេញក្នុបន្ទប់ សវនាការ ។

បន្ថែមពីនេះ ក្រុមអ្នកយកព័ត៌មាន ៣៩នាក់ រួមជាមួយបុគ្គលិកអង្គការជាតិ និងអន្តរជាតិ ក៏ចូលរួមតាមដាន សវនាការដែរ ។ នៅថ្ងៃសៀលបន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់ ប្រជាពលរដ្ឋ និងនិស្សិតបានចាកចេញពីសាលសវនាការ នៅសល់តែក្រុមអ្នកកាសែត និងបុគ្គលិកអង្គការជាតិ និងអន្តរជាតិប៉ុណ្ណោះ។

***បញ្ហាបកប្រែ :*** ការបកប្រែនៅសប្តាហ៍នេះ គឺមានលក្ខណៈល្អប្រសើរ ។ អ្នកបកប្រែហាក់សកម្មក្នុងការស្នើសុំឱ្យភាគីបើកប្រដាប់បំពងសម្លេងមុនធ្វើការឆ្លើយតប ដើម្បីឱ្យសំលេងឮដល់អ្នកបកប្រែ និងស្នើឱ្យភាគីនិយាយយឺតៗកុំឱ្យបានបង់ព័ត៌មាន ។ នៅថ្ងៃព្រហស្បត្តិ៍ មេធាវីការពារក្តីលោក **Roux** បានបង្អាក់ដំណើរការនីតិវិធីដោយស្នើសុំប្រធានអង្គជំនុំជម្រះ **និល នន់** ឱ្យសាក្សីនិយាយយឺតៗ ដើម្បីឱ្យអ្នកបកប្រែមានពេលគ្រប់គ្រាន់បកឱ្យបានត្រឹមត្រូវ មុនចាប់ផ្តើមសួរសំណួរថ្មី ។

***បញ្ចៀសសំណួរមិនពាក់ព័ន្ធ :*** នៅថ្ងៃចន្ទ ប្រធានអង្គជំនុំជម្រះ **និល នន់** បានបង្អាក់សំណួរដែលមិនពាក់ព័ន្ធលើកឡើងដោយមេធាវីដើមបណ្តឹងលោកស្រី **Studzinsky** ។ លោកស្រីប៉ុនប៉ងតាំងសំណួរយកព័ត៌មានពីអ្នកស្រី **ណាំ ម៉ុន** អំពីការបង្ខំឱ្យរៀបការនៅគុកព្រៃសរ ប៉ុន្តែប្រធានអង្គជំនុំជម្រះ **និល នន់** បានប្រើវិធាន ៩៨(២) បង្អាក់សំណួរ ដោយពន្យល់ថា សំណួរនោះមិនអនុញ្ញាតិឱ្យសួរទេ ព្រោះមិនពាក់ព័ន្ធអង្គហេតុ ដែលសាក្សីផ្តល់សក្ខីកម្ម ។

***ឥរិយាបថកើតមានក្នុងសវនាការ :*** នៅថ្ងៃអង្គារ អង្គជំនុំជម្រះបានដាស់តឿនដល់ភាគីពាក់ព័ន្ធនឹងការមិនគោរពវិធានសវនាការ គឺឡើងបញ្ចេញយោបល់ដោយមិនសុំការអនុញ្ញាតិជាមុនពីប្រធាន ។

## តារាងគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | ម៉ោងបញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ថ្ងៃចន្ទ ១៣-០៧-០៩ | ០៩:០០ | ១០:២០-១០:៤០ | ១២:០០-១៣:៣០ | ១៤:៣០-១៤:៥០ | ១៥:១៥ | ៤ ម៉ោ០៥ នាទី |
| ថ្ងៃអង្គារ៍ ១៤-០៧-០៩ | ០៩:១០ | ១០:៣០-១០:៥៥ | ១២:០៥-១៣:៣០ | ១៤:៤៥-១៥:០៥ | ១៦:១០ | ៤ ម៉ោ៥០ នាទី |
| ពុធ ១៥-០៧-០៩ | ០៩:០៥ | ១០:៤០-១១:០៥ | ១១:៥០- ១៣:៣០ | ១៤:៣៥-១៥:១០ | ១៥:២៥ | ៣ ម៉ោ៤០ នាទី |
| ព្រហស្បត្តិ៍ ១៦-០៧-០៩ | ០៩:០៥ | ១០:៣០-១០:៥៥ | ១២:០០-១៣:៣៥ | ១៤:៤០– ១៥:០០ | ១៦:២៥ | ៥ ម៉ោ ០០ នាទី |

ចំនួនម៉ោងជាមធ្យម : ៤ម៉ោ ០៩នាទី

ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៦ម៉ោ ៣៥នាទី

ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ១៩៤ម៉ោ ៤៥នាទី នៃ ៤២ ថ្ងៃសវនាការ នៃសប្តាហ៍ទី ១២

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** ( "កម្មវិធី" ) ៖ ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ( អ.វ.ត.ក ) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម ៖

**ក្រុមទី១**

- លោកស្រី **ជូ វិនាថ** ៖ ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** ៖ បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** ៖ សិង្ហបុរី
- លោក **Florian Hansen** ៖ អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** ៖ ស្វីស
- កញ្ញា **Deepika Sharma** ៖ សហរដ្ឋអាមេរិក

**ក្រុមទី២**

- កញ្ញា **សេក សុវណ្ណា** ៖ មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** ៖ បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** ៖ ឥណ្ឌូនេស៊ី
- កញ្ញា **Delphia Lim Hui Min** ៖ សិង្ហបុរី
- កញ្ញា **Binxin Zhang** ៖ ចិន
- លោក **Jaspreet Dosanjh** ៖ សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឍមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/ ។